**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាឧទ្ធរណ៍

**<u>តាងនាមប្រជារាស្ត្រខ្មែរ</u>**

សាលាឧទ្ធរណ៍ភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ

លេខ ១៩៣/០២-០៣-១២

**<u>សាលដីកា</u>**

លេខ ១១ ក្រ"ឃ"ចុះ

ថ្ងៃទី ១២-០២-២០១៤

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ០៦ក្រ ចុះថ្ងៃទី ០៨-០២-៩៣ បានបើកសវនាការជាសាធារណៈ នៅសាលាឧទ្ធរណ៍នាថ្ងៃទី ០៦-០២-១៤ ដែលមានសមាសភាពដូចតទៅ៖

**<u>សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ</u>**

លោក [redacted] ប្រធាន

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

**<u>តំណាងមហាអយ្យការ</u>**

លោក [redacted]

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោក [redacted]

បានបើកសវនាការជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌដែលមានលេខ ១៩៣ ចុះថ្ងៃទី ០២-០៣-២០១២ រវាង ៖

-<u>ជនជាប់ចោទឈ្មោះ</u>

១-[redacted] **សម្បត្តិ** ហៅ **ខ្ញែក** ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរ មុខរបរ លក់ដូរ កើតនៅភូមិសន្សំកុសល សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ មានទីលំនៅសព្វថ្ងៃផ្លូវលំ [redacted] ឪពុកឈ្មោះ [redacted]"ស" ម្តាយឈ្មោះ [redacted]"រ" នៅលីវ ទោសពីមុនធ្លាប់ជាប់ពន្ធនាគារ ០២ឆ្នាំ"ឃុំខ្លួន" (ប្តឹងឧទ្ធរណ៍)។ មានមេធាវីការពារសិទ្ធិឱ្យឈ្មោះ [redacted] **ម៉ាច**។

២-[redacted] **សម្បត្តិ** ហៅ [redacted] **សុភាព** ភេទប្រុស អាយុ២៣ឆ្នាំ ជាតិខ្មែរ មុខរបរ កម្មករទឹកសុទ្ធ ទីកន្លែងកំណើតភូមិខ្វារ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ទីលំនៅភូមិ [redacted] ឪពុកមិនស្គាល់ឈ្មោះ ម្តាយឈ្មោះ [redacted]"រ" នៅលីវ ទោសពីមុនគ្មាន"ឃុំ ខ្លួន" (ប្តឹងឧទ្ធរណ៍)។ មានមេធាវីការពារសិទ្ធិឱ្យឈ្មោះ [redacted] **ម៉ាច**។

៣-[redacted] **ឌី** ហៅ **ច័ន្ទ** ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ.. (មិនប្តឹងឧទ្ធរណ៍)។



ផ្លូវសម្តេចសុធារស សាលាឧទ្ធរណ៍-មហាអយ្យការ (ទល់មុខព្រះបរមរាជវាំង ក្នុងបរិវេណក្រសួងយុត្តិធម៌)

៤-[redacted] ថារី ភេទប្រុស អាយុ៤៨ឆ្នាំ ជាតិខ្មែរ .. (មិនប្តឹងឧទ្ធរណ៍)។

**ត្រូវជាប់ចោទពីបទ** ៖ អំពើលួច មានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សានិងកាន់កាប់ ឬដឹកជញ្ជូនអាវុធដោយគ្មានការអនុញ្ញាត។

ប្រព្រឹត្តនៅផ្ទះលេខ ១៦អា ផ្លូវលេខ៣៣០ សង្កាត់បឹងកេងកងទី៣ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៥-០៥-២០១១ តាមបញ្ញត្តិមាត្រា ៣៥៣,៣៥៧,៤៩០ នៃក្រមព្រហ្មទណ្ឌ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ៖

១-[redacted] ស៊ីលេត ភេទស្រី អាយុ២៩ឆ្នាំ ជាតិខ្មែរ មុខរបរ បុគ្គលិកក្រុមហ៊ុនដឹកជញ្ជូន មានទីលំនៅផ្ទះលេខ[redacted]។

២-[redacted] សារឿន ភេទប្រុស អាយុ៣៧ឆ្នាំ ជាតិខ្មែរ មុខរបរ នគរបាលជាតិ មានទីលំនៅផ្ទះលេខ[redacted]។

**ឯរឿងហេតុមានដូចតទៅ**

កាលពីថ្ងៃទី ១៥-០៥-២០១១ វេលាម៉ោង ៩.៣០នាទី នៅចំណុចផ្ទះលេខ១៦អា ផ្លូវលេខ៣៣០ សង្កាត់បឹងកេងកងទី៣ ខណ្ឌចំការមន រាជធានីភ្នំពេញ មានករណីលួចគាស់ផ្ទះឈ្មោះ [redacted] សារឿន ដោយម្ចាស់ផ្ទះបានបាត់ម៉ូតូចំនួន០២គ្រឿង ម៉ាកអ៊ែរប្លេក និងម៉ាក គុប៥០ កុំព្យូទ័រមួយគ្រឿង និងសំភារៈមួយចំនួន។ រហូតដល់ថ្ងៃទី ២៥-០៥-២០១១ ទើបសមត្ថកិច្ចឃាត់ខ្លួនឈ្មោះ [redacted] សម្បត្តិ យកមកសាកសួរ ហើយបានសារភាពថា ខ្លួននិងបក្ខពួកឈ្មោះ ង៉ុយ, [redacted] ភាព, [redacted] សម្បត្តិ ពិតជាបានលួចគាស់ផ្ទះយកទ្រព្យសម្បត្តិកាលពីថ្ងៃទី ១៥-០៥-២០១១ ប្រាកដមែន។ ពេលធ្វើសកម្មភាពខ្លួនប្រើប្រាស់អាវុធខ្លីម៉ាក កា៥៤ និងសំភារៈគាស់ផ្ទះមួយចំនួន។ ចំណែកម៉ូតូលួចទាំងពីរលើកបានយកទៅលក់ឱ្យឈ្មោះ [redacted] ឌី ហៅ វ័ន្ត និងគ្រឿងអលង្កាលក់ឱ្យឈ្មោះ [redacted] ថារី។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ១៤៣ក្រ៖"ប" ចុះថ្ងៃទី ០៨-១២-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានខ្លឹមសារសម្រេចដូចខាងក្រោម៖

១-ផ្ដន្ទាទោសលើឈ្មោះ

ក-[redacted] សម្បត្តិ ហៅ ខ្វែក ភេទប្រុស អាយុ១៨ឆ្នាំ។

ខ-[redacted] សម្បត្តិ ហៅ [redacted] សុភាព ភេទប្រុស អាយុ២៣ឆ្នាំ។

ដាក់ពន្ធនាគារក្នុងម្នាក់ៗ កំណត់០៤"បួន"ឆ្នាំ និងពិន័យជាប្រាក់ក្នុងម្នាក់ៗ ចំនួន ១ ០០០ ០០០៛"មួយលាន"រៀល។

ពីបទ: អំពើលួច មានស្ថានទម្ងន់ទោសដោយសារគារប្រព្រឹត្តអំពើហិង្សា និងកាន់កាប់ ឬដឹកជញ្ជូនអាវុធដោយគ្មានការអនុញ្ញាត ប្រព្រឹត្តនៅផ្ទះលេខ១៦អា ផ្លូវលេខ៣៣០ សង្កាត់បឹងកេងកងទី៣ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៥-០៥-២០១១។ បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្ដន្ទាទោសតាមមាត្រា ៣៥៧ ,៤៩០ នៃក្រមព្រហ្មទណ្ឌ។

២-ផ្ដន្ទាទោសលើឈ្មោះ [redacted] ឌី ហៅ វ័ន្ត ភេទប្រុស អាយុ២៥ឆ្នាំ ដាក់ពន្ធនាគារកំណត់០៥"ប្រាំ"ឆ្នាំ តែទោសនេះត្រូវអនុវត្តគឺ:

-ទោសដាក់ពន្ធនាគារចំនួន ០២"ពីរ"ឆ្នាំ

-ទោសដែលនៅសល់ចំនួន ០៣"បី"ឆ្នាំ ត្រូវព្យួរទោសជម្មតាទាំងអស់។



Scanned with CamScanner

ពីបទ: អំពើទទួលផលចោរកម្មមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅផ្ទះលេខ១៦អា ផ្លូវលេខ ៣៣០ សង្កាត់បឹងកេងកងទី៣ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៥-០៥-២០១១។ បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមមាត្រា ១០៨ ,៤០១ នៃក្រមព្រហ្មទណ្ឌ។

៣-ឱ្យរួចខ្លួនពីបទចោទលើឈ្មោះ [redacted] ថាវី ភេទប្រុស អាយុ៤៨ឆ្នាំ ពីបទ: អំពើទទួលផលចោរកម្ម ប្រព្រឹត្តនៅផ្ទះលេខ១៦អា ផ្លូវលេខ៣៣០ សង្កាត់បឹងកេងកងទី៣ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៥-០៥-២០១១។ បទល្មើសព្រហ្មទណ្ឌដែលត្រូវផ្តន្ទាទោសតាមមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ។

៤-បង្គាប់ឱ្យឈ្មោះ [redacted] សម្បត្តិ ហៅ ខ្វែក ,ឈ្មោះ [redacted] សម្បត្តិ ហៅ [redacted] សុភាព និងឈ្មោះ [redacted] ឌី ហៅ វ័ន្ត រួមគ្នាសងសំណងរដ្ឋប្បវេណីចំនួន ៥ ០០០ ០០០៛ "ប្រាំលាន"រៀល ឱ្យទៅឈ្មោះ [redacted] ស៊ីលេត និងចំនួន ៥ ០០០ ០០០៛"ប្រាំលាន" រៀលទៀតឱ្យទៅឈ្មោះ [redacted] សារឿន។ ការទាមទារលើសពីនេះបដិសេធចោល។ តាមមាត្រា ២៣,៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៥-បង្គាប់ឱ្យប្រគល់ប្រាក់ចំនួន ៦ ០០០ ០០០៛ "ប្រាំមួយលាន" រៀល (មានបង្កាន់ដៃទទួលប្រាក់លេខ ២២ ចុះថ្ងៃទី ៣០-០៥-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ) ឱ្យទៅឈ្មោះ [redacted] ថាវី វិញ។

៦-រឹបអូសយកនូវ:

ក-គ្រាប់កាំភ្លើងខ្លីម៉ាក កា៥៤ ចំនួន ០៤គ្រាប់ ត្រូវរឹបអូសបំផ្លាញចោល។

ខ-ម៉ូនីទ័រ LCD ០២គ្រឿង ម៉ាក HALER

គ-ម៉ូនីទ័រ LCD ០១គ្រឿង ម៉ាក SAMSUNG

ឃ-LAPTOP ចំនួន ០២គ្រឿង ម៉ាក DELL-TOSHIBA "ខូចគុណភាព"។

ង-ប្រដាប់ទប់ភ្លើងកុំព្យូទ័រចំនួន ០២គ្រឿង។

ច-ម៉ាស៊ីន CPU ម៉ាក DELL ចំនួន ០២គ្រឿង "មួយគ្រឿងរបើករបក"

ឆ-ម៉ាស៊ីនព្រីនធ័រ ចំនួន ០២គ្រឿង ម៉ាក HP-CANNON

ជ-អំភ្លីចំនួន ០២គ្រឿង

ឈ-ឌុយ NETWORK ម៉ាក TP LINK ចំនួន ០១គ្រឿង

ញ-KEYBORD ម៉ាក DELL ចំនួន០១

ដ-ឧបករណ៍ភ្ជាប់កុំព្យូទ័រមួយចំនួន

ឋ-ទូរស័ព្ទចំនួន០១គ្រឿង TOSHIBA មួយគ្រឿង និងតេឡេសំរាប់បញ្ជាទូរទស្សន៍

ឌ-កាបូបកុំព្យូទ័រចំនួន ០៣

ឍ-ទូរទស្សន៍ម៉ាក TOSHIBA មួយគ្រឿង និងតេឡេសំរាប់បញ្ជាទូរទស្សន៍ មួយគ្រឿង។

ណ-ម៉ូតូមួយគ្រឿងម៉ាកវីវ៉ា ស៊េរី ២០០៤ ពាក់ស្លាកលេខ 1D 6701 លេខតួ BE4CCTH 111615 និងលេខម៉ាស៊ីន E443-TH111615។

ត-កូនសោររថយន្តចំនួន ០១គ្រឿង ត្រូវប្រគល់ឱ្យម្ចាស់ដើមវិញ។

៧-សាលក្រមនេះជំនុំជម្រះ នៅថ្ងៃទី ២៨-១១-២០១១ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ០៨-១២-២០១១ ចំពោះមុខជនជាប់ចោទឈ្មោះ សំ សម្បត្តិ ហៅ ខ្វែក ,ជា សម្បត្តិ ,ហ៊ួយ ឌី ហៅ វ័ន្ត ,ផេន ថាវី កំបាំងមុខជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ឡុង ស៊ីលេត, សូ សារឿន



Scanned with CamScanner

មុករយៈពេលប្តឹងទាស់ និងបើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ០៩-១២-២០១១ របស់ឈ្មោះ [redacted] សម្បត្តិ និងឈ្មោះ [redacted] សម្បត្តិ សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១៩៣ក្រ៦"ប" ចុះថ្ងៃទី ០៨-១២-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញរបាយការណ៍របស់ចៅក្រមសាលាឧទ្ធរណ៍ចុះថ្ងៃទី ២៦-០៨-២០១២។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការចុះថ្ងៃទី ២៨-០៩-២០១២ ។

**នាពេលសវនាការសាលាឧទ្ធរណ៍**

ចៅក្រមអានរបាយការណ៍រឿង

-ក្រឡាបញ្ជីអានចម្លើយឈ្មោះ [redacted] ស៊ីលេត, [redacted] សាវឿន

-ឈ្មោះ [redacted] សម្បត្តិ បានឆ្លើយថា ខ្លួនប្តឹងឧទ្ធរណ៍រឿងផ្តន្ទាទោសច្រើនពេក ខ្លួនសុខចិត្តទទួលស្គាល់អង្គហេតុដែលបានកើតឡើង។ ខ្លួនសំណូមពរសុំឱ្យតុលាការជួយបន្ធូបន្ថយទោស។

-ឈ្មោះ [redacted] សម្បត្តិ បានឆ្លើយថា ខ្លួនសុខចិត្តទទួលស្គាល់អង្គហេតុដែលបានកើតឡើង។ពីមុនមកខ្លួនមិនដែលមានទោសទេ ខ្លួនមិនសុខចិត្តដោយចង់មកសារភាពក្នុងរឿងនេះ។ ក្រុមខ្លួនចូលទៅគាស់ផ្ទះមិនមានអាវុធទេ ហើយចំពោះគ្រាប់កាំភ្លើងជារបស់ឈ្មោះ ភាព ដែលបានទុកនៅក្នុងផ្ទះខ្លួន។ ខ្លួនសំណូមពរសុំឱ្យតុលាការជួយបន្ធូបន្ថយទោស។

**តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋានថា**

-ដោយអង្គហេតុនៅក្នុងសំណុំរឿងលួចមានស្ថានទម្ងន់នេះជាអង្គហេតុមិនប្រែប្រួល ហើយជនជាប់ចោទទាំងពីរក៏បានសារភាពនូវចំពោះមុខក្រុមប្រឹក្សាជំនុំជម្រះ។ ជាគោលការណ៍ប្រសិនបើជនបានប្រព្រឹត្តបទល្មើសហើយស្គាល់ទោសកំហុសរបស់ខ្លួន គួរក្រុមប្រឹក្សាជំនុំជម្រះអាចបន្ធូបន្ថយខ្លះ។ ដូច្នេះតំណាងមហាអយ្យការសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះបន្ធូបន្ថយតាមការស្នើសុំរបស់ជនជាប់ចោទ។

-មេធាវី [redacted] ម៉ាច ការពារសិទ្ធិឱ្យឈ្មោះ [redacted] សម្បត្តិ , [redacted] សម្បត្តិ បានធ្វើសេចក្តីសន្និដ្ឋានថាខ្លួនឯកភាពចំពោះការលើកឡើងរបស់តំណាងមហាអយ្យការ ហើយអង្គហេតុនៃសំណុំរឿងនេះកូនក្តីខ្លួនទទួលស្គាល់ អ្វីដែលគាត់ប្តឹងឧទ្ធរណ៍នេះត្រង់ចំណុចទណ្ឌកម្ម និងសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះពិចារណាឡើងវិញអំពីចំណុចទណ្ឌកម្មនេះ ហើយអំពើរបស់គាត់ប្រព្រឹត្តឡើងដោយអាចិកំបាំង និងសំណូមពរសុំឱ្យក្រុមប្រឹក្សាពិចារណាអំពីស្ថានសម្រាលទោសអប្បបរមា តាមមាត្រា ៣៥៧ នៃច្បាប់។

**សភាព្រហ្មទណ្ឌយល់ឃើញថា**

១-បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ០៩-១២-២០១១ របស់ជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ និងឈ្មោះ [redacted] សម្បត្តិ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១៩៣ក្រ៦"ប" ចុះថ្ងៃទី ០៨-១២-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ធ្វើឡើងក្នុងកំណត់ច្បាប់ តាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សភាព្រហ្មទណ្ឌអាចទទួលជំនុំជម្រះបាន។

២-ជនជាប់ចោទឈ្មោះ [redacted] សម្បត្តិ និងឈ្មោះ [redacted] សម្បត្តិ បានឆ្លើយសារភាពនូវអំពើប្រព្រឹត្ត



Scanned with CamScanner

របស់ខ្លួន និងសុំឱ្យតុលាការបន្ធូបន្ថយទោសដល់ខ្លួន ព្រោះខ្លួនបានដឹងនូវកំហុសរបស់ខ្លួនហើយ។

៣-រឿងក្តីនេះសាលាដំបូងបានធ្វើការស៊ើបសួរ និងលើកយកសំអាងហេតុមកបញ្ជាក់មានលក្ខណៈច្បាស់លាស់ហើយ ហេតុដូច្នេះសភាព្រហ្មទណ្ឌ ឯកភាពតាមសំអាងហេតុនេះទាំងស្រុង ពុំចាំបាច់លើកយកសំអាងហេតុដដែលនេះមកបញ្ជាក់ជាថ្មីទៀតទេ។

៤-មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted]សម្បត្តិ និងឈ្មោះ [redacted]សម្បត្តិ ពីបទអំពើលួចមានស្ថានទម្ងន់ទោស ដោយសារការប្រព្រឹត្តអំពើហិង្សា និងកាន់កាប់ ឬ ដឹកជញ្ជូនអាវុធដោយគ្មានការអនុញ្ញាត, ប្រព្រឹត្តនៅផ្ទះលេខ១៦អា ផ្លូវលេខ៣៣០ សង្កាត់បឹងកេងកងទី៣ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៥-០៥-២០១១។ តាមមាត្រា ៣៥៧ ,៤៩០ នៃក្រមព្រហ្មទណ្ឌ។

៥-តាមសំណូមពររបស់ជនជាប់ចោទទាំងពីរសុំឱ្យសភាព្រហ្មទណ្ឌបន្ធូបន្ថយទោសដល់ខ្លួននោះ សភាព្រហ្មទណ្ឌមិនលើកយកមកពិចារណាទេ ព្រោះតាមអំណាចសាលក្រមនេះបានសម្រេចផ្តន្ទាទោសលើជនជាប់ចោទទាំងពីររូបនេះមានកំរិតទាបហើយ។

៦-សាលក្រមព្រហ្មទណ្ឌលេខ ១៨៣ក្រ៦"ប" ចុះថ្ងៃទី ០៨-១២-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ សម្រេចសេចក្តីមានលក្ខណៈត្រឹមត្រូវហើយ គួរតម្កល់ទុកជាបានការដដែល។

ហេតុដូច្នេះ

**វិនិច្ឆ័យសេចក្តី**

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ០៩-១២-២០១១ របស់ជនជាប់ចោទឈ្មោះ [redacted]សម្បត្តិ និងឈ្មោះ [redacted]សម្បត្តិ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៨៣ក្រ៦"ប" ចុះថ្ងៃទី ០៨-១២-២០១១ របស់សាលាដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល។

៣-សាលដីកានេះប្រកាសជាសាធារណៈ នៅថ្ងៃទី ១២-០២-២០១៤ ចំពោះមុខមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ និងជនជាប់ចោទ, កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី។

-បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកំលាំងប្រដាប់អាវុធគ្រប់ថ្នាក់ គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| [redacted] | [redacted] | [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម។

បានឃើញ

**ប្រធានសាលាឧទ្ធរណ៍**

[redacted]

សាលាឧទ្ធរណ៍ថ្ងៃទី ២៥ ខែ ០៦ ឆ្នាំ ២០១៤

**ក្រឡាបញ្ជី**

[redacted]



២៣៣